# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Sep-2011, 14:07
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹង "ការជំទាស់របស់ អៀង សារី នៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន"

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក អាង ឧត្តម

លោក Michael G.KARNAVAS

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

លោក ស សូវ៉ាន

លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១១ មេធាវីការពារក្តី អៀង សារី ("មេធាវីការពារក្តី") បានដាក់*ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន ("ការជំទាស់")*[1]។ ពួកគេតវ៉ាថា "មានឯកសារខ្លះក្នុងប្រភេទឯកសារ[មួយចំនួន] មិនបានបំពេញតាមកម្រិតអប្បបរមានៃយថាភូត ភាពអាចជឿទុកចិត្តបាន និងភាពពាក់ព័ន្ធ" និងថាជាផលវិបាក ប្រភេទឯកសារទាំងនេះ "មិនអាចទទួលយកបានឡើយ"[2]។ ពួកគេស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង "តម្រូវឱ្យគូភាគីបង្ហាញនូវយថាភូត ភាពអាចជឿទុកចិត្តបាន និងភាពពាក់ព័ន្ធ" នៃឯកសារនានាដែលពួកគេបង្ហាញ ដើម្បីអាចទទួលយកបាន និងដើម្បី "បដិសេធចោលឯកសារនានាដែលមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យអប្បបរមាទាំងនេះ[3]។

២- សហព្រះរាជអាជ្ញាស្នើជូនថា (១) ការជំទាស់នេះគឺជាការមិនចាំបាច់ មានភាពផ្ទុយគ្នា និងស្រពិចស្រពិល មិនអាចទទួលយកបានចំពោះភស្តុតាងដែលបានបដិសេធ និងដំណោះស្រាយដែលបានស្វែងរក; (២) ការសាកល្បងផ្នែកច្បាប់ដូចបានអះអាងដោយមេធាវីការពារក្តីចំពោះភាពអាចទទួលយកបាននៃភស្តុតាង គឺជាការមិនត្រឹមត្រូវតាមច្បាប់ទាក់ទងនឹងចំណុចជាក់លាក់ខ្លះ និង (៣) ការជំទាស់ដូចបានអះអាងនេះ គឺគ្មានភស្តុតាងជាសំអាងទេ ហើយក៏មិនបង្ហាញឱ្យឃើញឱ្យបានគ្រប់គ្រាន់ថាប្រភេទភស្តុតាងដែលកំពុងតវ៉ា ក៏មិនអាចទទួលយកបានដែរ។ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងបដិសេធចោលការជំទាស់ទាំងនេះ និងបង្គាប់ឱ្យគូភាគីនានាថាការជំទាស់ទៅនឹងឯកសារណាមួយនៅពេលអនាគត ត្រូវដាក់នៅក្នុងអម្លុងពេលកំណត់ និងតាមរបៀបមួយជាក់លាក់គ្រប់គ្រាន់ដើម្បីបង្កលក្ខណៈឱ្យអង្គជំនុំជម្រះសាលាដំបូងអាចវាយតម្លៃបានលើការជំទាស់ទាំងនោះ។

## II. ប្រវត្តិនីតិវិធី

៣- នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ("ដីកាបង្គាប់រៀបចំសវនាការបឋម") ដោយបង្គាប់ឱ្យគូភាគីទាំងអស់ដាក់

---

[1] **E114** ការជំទាស់, ៦ កញ្ញា ២០១១ ។

[2] *ក្នុងឯកសារដដែលដូចខាងលើ*, ត្រង់ទំព័រទី១ ។

[3] *ក្នុងឯកសារដដែលដូចខាងលើ*, ត្រង់ទំព័រទី១៤ ។

"បញ្ជីឯកសារ និងវត្ថុតាង" ត្រឹមថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១[4] ដែលកាលបរិច្ឆេទនេះ ក្រោយមកត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[5]។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារដែលខ្លួនមានបំណងចង់ពឹងផ្អែកនៅពេលសវនាការ[6]។

៤- នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់ *បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមានក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*[7]។ ការដាក់ឯកសារនេះបានភ្ជាប់មកជាមួយនឹងឧបសម្ព័ន្ធមួយដែលមានចំនួន១,៣៨៩ទំព័រ រាយបញ្ជីឯកសារគ្រប់ទាំងអស់ដែលមាននៅក្នុងសំណុំរឿងសម្រាប់សំណុំរឿងលេខ០០២[8] និងបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួន"មានសិទ្ធិពឹងផ្អែកលើឯកសារណាមួយក៏បានក្នុងសំណុំរឿង"[9] (សង្កត់ន័យត្រង់ពាក្យមានគូសបន្ទាត់ពីក្រោម)។ មេធាវីការពារក្តីបានដាក់សារណាទីពីរ និងទីបីទៀត ដើម្បីជាការឆ្លើយតបទៅនឹងដីកាបង្គាប់រៀបចំសវនាការបឋម គឺនៅថ្ងៃទី៨ និងទី១៩ ខែមេសា ឆ្នាំ២០១១ ជាបន្តបន្ទាប់[10]។ សារណាទីពីរបានបញ្ចូលនូវឧបសម្ព័ន្ធមួយមានចំនួន ៥៦០ទំព័រ ដោយចុះបញ្ជីឯកសារទាំងអស់ដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម[11]។ សារណាទីបីបានដាក់បញ្ចូលឧបសម្ព័ន្ធមួយចុះបញ្ជីឯកសារថ្មីដែលមានចំនួន១,០៣៧ទំព័រ ដាក់ជូនអង្គជំនុំជម្រះសាលាដំបូង[12] និងបានបញ្ជាក់យ៉ាងច្បាស់អំពីការរក្សា "សិទ្ធិ" របស់មេធាវីការពារក្តីក្នុងការបំពេញបន្ថែមលើបញ្ជីឯកសាររបស់ខ្លួននៅពេលក្រោយ[13]។

---

[4] **E9** ដីកាបង្គាប់រៀបចំសវនាការបឋម, ១៧ មករា ២០១១, *ត្រង់* កថាខ័ណ្ឌទី១២ ។

[5] **E68** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ២៨ មីនា ២០១១ ។

[6] **E9/31** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣), ១៩ មេសា ២០១១ ("បញ្ជីឯកសារទីមួយរបស់សហព្រះរាជអាជ្ញា") ។

[7] **E9/22** *បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមានក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*, ១ មេសា ២០១១ ("បញ្ជីឯកសារទីមួយរបស់មេធាវីការពារក្តី") ។

[8] **E9/22.2** ឧបសម្ព័ន្ធ ក: បញ្ជីឯកសារសំណុំរឿង ០០២ ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១, ១ មេសា ២០១១ ។

[9] **E9/22** បញ្ជីឯកសារទីមួយរបស់មេធាវីការពារក្តី, កំណត់សំគាល់*ខាងដើមទី៧* ត្រង់កថាខ័ណ្ឌទី១៣, ៣៨ ។

[10] **E9/24** បញ្ជីឯកសារបឋមទីពីររបស់ អៀង សារី, ៨ មេសា ២០១១ ("បញ្ជីឯកសារទីពីររបស់មេធាវីការពារក្តី") ។ **E9/25** បញ្ជីឯកសារបឋមទីបីរបស់ អៀង សារី, ១៩ មេសា ២០១១ ("បញ្ជីឯកសារទីបីរបស់មេធាវីការពារក្តី") ។

[11] **E9/24.2** ឯកសារក្នុងឃ្លាំងផ្ទុកឯកសាររួម, ៨ មេសា ២០១១ ។

[12] **E9/25.2** ឧបសម្ព័ន្ធ: បញ្ជីឯកសារ និងវត្ថុតាង - អៀង សារី, ១៩ មេសា ២០១១ ។

[13] **E9/25** បញ្ជីឯកសារទីបីរបស់មេធាវីការពារក្តី, កំណត់សំគាល់*ខាងដើមទី១០* ត្រង់ទំព័រទី២ ។

៥- នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ក្នុងអម្លុងពេលសវនាការបឋមសម្រាប់សំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីកំណត់ត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ នូវអត្តសញ្ញាណឯកសារ និងវត្ថុតាងនានាដែលខ្លួនបានពិចារណាថា មានការពាក់ព័ន្ធទៅនឹងដំណាក់កាលទាំងបួននៃសវនាការបឋម[14]។ សហព្រះរាជអាជ្ញាបានដាក់បញ្ជីបន្ថែម ដើម្បីជាការឆ្លើយតបទៅនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[15]។

៦- នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់ *បញ្ជីឯកសារ និងវត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង*[16]។ ការដាក់ឯកសារនេះភ្ជាប់មកជាមួយនឹងឧបសម្ព័ន្ធនៃបញ្ជីឯកសារចំនួនប្រាំបី ដែលមេធាវីការពារក្តីមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[17] និងបានរក្សា "សិទ្ធិ" របស់មេធាវីការពារក្តី "ដើម្បីដាក់បន្ថែមទៅលើបញ្ជីឯកសារនេះ ពីបញ្ជីឯកសាររបស់ខ្លួនសម្រាប់សវនាការទាំងមូល និងពីប្រភពផ្សេងទៀត"[18]។ ការដាក់ឯកសារនេះក៏បានលើកឡើងវិញ អំពីការជំទាស់ដែលបានលើកឡើងកាលពីលើកមុនដោយមេធាវីការពារក្តីទៅនឹងការទទួលយកនូវឯកសារចំនួនបីប្រភេទ ដែលបានដាក់បញ្ចូលម្តងទៀតក្នុងការជំទាស់នេះ មានដូចជា៖ សម្ភារៈពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") "ភ័ស្តុតាងបានមកដោយការធ្វើទារុណកម្ម" និងកំណត់ហេតុ និងការស្តាប់ចម្លើយរបស់បុគ្គលនានាដែលមិនអាចចូលមកចំពោះមុខនៅពេលសវនាការ។

## III. ច្បាប់ជាធរមាន

៧- វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ("វិធាន") គឺជាចំណុចចាប់ផ្តើមសម្រាប់ធ្វើការវិភាគអំពីបញ្ហានៃភាពអាចទទួលយកបាននៃភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក[19]។ វិធាន៨៧(១)ចែងថា "រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក"។ វិធាននេះត្រូវកម្រិតដោយវិធាន៨៧(៣) ដែលចែងអំពី

[14] **E1/4.1** ប្រតិចារិកនៃសវនាការបឋម, ២៧ មិថុនា ២០១១, ត្រង់ទំព័រទី២៥ ។

[15] **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារទាក់ទងនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ២២ កក្កដា ២០១១ ("បញ្ជីឯកសារទីពីររបស់សហព្រះរាជអាជ្ញា") ។

[16] **E109/6** បញ្ជីឯកសារ និងវត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង, ៨ សីហា ២០១១ ("បញ្ជីឯកសារទីបួនរបស់មេធាវីការពារក្តី") ។

[17] **E109/6.2** ឧបសម្ព័ន្ធ: បញ្ជីឯកសារ និងវត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង, ៨ សីហា ២០១១ ។

[18] **E109/6** បញ្ជីឯកសារទីបួនរបស់មេធាវីការពារក្តី, កំណត់សំគាល់*ខាងដើមទី១៦* ត្រង់ទំព័រ១ ។

[19] វិធាន (វិសោធនកម្មលើកទី៨), ដែលបានកែប្រែនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១ ។

មូលហេតុជាក់លាក់អំពីភ័ស្តុតាងបែបណាដែលអាចច្រានចោល មានដូចជាភ័ស្តុតាង (ក) មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា; (ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ; (គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង; (ឃ) ច្បាប់មិនអនុញ្ញាត ឬ (ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។ វិធានស្តីពីភាពអាចទទួលយកបានទាំងនេះ គឺស៊ីសង្វាក់គ្នានឹងវិធាននានាដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ។

### *i. ភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន គឺជាចំណុចស្នូលដ៏សំខាន់នៃការទទួលយក*

៨- អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយអំពីអានុភាពនៃវិធាន៨៧(៣)ថា តម្រូវឱ្យភ័ស្តុតាងបំពេញតាម "លក្ខខណ្ឌជាក់លាក់មួយចំនួននៃភាពពាក់ព័ន្ធ និងតម្លៃភស្តុតាង" និង "បទដ្ឋានអប្បបរមានៃភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន" *ដើម្បីឱ្យទទួលយកបាន*[20]។

៩- ដើម្បីពិចារណាថា មានភាពពាក់ព័ន្ធ ភ័ស្តុតាងនោះត្រូវតែជាសម្ភារៈ*មានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្កើតជាអង្គហេតុមួយ*ចំពោះបញ្ហា និងទំនងជាបង្កើតបាននូវគោលជំហររបស់ភាគី[21]។ បើសិនលក្ខណៈវិនិច្ឆ័យនេះត្រូវបានបំពេញនោះ ចំណោទត្រូវបង្វែរទៅរកភាពជឿទុកចិត្តបាននៃភ័ស្តុតាងវិញម្តង។

១០- ដើម្បីឱ្យចាត់ទុកថាអាចឱ្យពឹងផ្អែកបាន ភ័ស្តុតាងដែលស្នើផ្តល់ជូននោះ តោងតែជាភ័ស្តុតាងដែលគួរឱ្យជឿទុកចិត្តបានដោយ*គ្រាន់តែមើលឃើញមួយក្រឡេកភ្នែក* ប្រភេទសម្រាប់ធ្វើការវាយតម្លៃបែបនេះ

---

[20] សូមអាន **E188** *ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្គេចអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ ០០១, សាលក្រម, ២៦ កក្កដា ២០១០ ("សាលក្រម ឌុច"), ត្រង់កថាខ័ណ្ឌទី៤១ ។ **E43/4** *ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្គេចអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ ០០១, សេចក្តីសម្រេចស្តីពី ភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភ័ស្តុតាង, ២៦ ឧសភា ២០០៩ ("សេចក្តីសម្រេចស្តីពីភ័ស្តុតាងក្នុងករណី ឌុច"), ត្រង់កថាខ័ណ្ឌទី៧ ។ **E176** សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(២), ២៨ តុលា ២០០៩, ("សេចក្តីសម្រេចលើសំណើនានាអនុលោមតាមវិធាន៨៧(២) ក្នុងករណី ឌុច"), ត្រង់កថាខ័ណ្ឌទី៣ ។

[21] សូមអាន *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ: ICC-01/04-01/06, ការកែតម្រូវពាក្យ/អក្សរនៃសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននូវឯកសារចំនួនបួន (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC), ២០ មករា ២០១១, ត្រង់កថាខ័ណ្ឌទី២៧ ("ដំបូង, អង្គជំនុំជម្រះត្រូវឱ្យប្រាកដថា ភ័ស្តុតាងនោះមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតជាអង្គហេតុមួយចំពោះសវនាការ ដែលក្នុងនោះគឺពាក់ព័ន្ធនឹងបញ្ហានានាដែលមានលក្ខណៈត្រឹមត្រូវដើម្បីពិចារណាដោយអង្គជំនុំជម្រះ...") ។

ពឹងផ្អែកទៅលើកាលៈទេសៈដោយឡែកៗសំរាប់ករណីនីមួយៗ[22]។ ទោះបីជាការធ្វើយថាភូតរបស់ឯកសារ (និយាយម៉្យាងទៀតថាឯកសារដែលត្រូវបានគេពោលអះអាងថាជាអ្វីនោះ) ទាក់ទងទៅនឹងភាពដែលគួរឱ្យសង្ស័យទុកចិត្តបាននៃឯកសារ ការធ្វើយថាភូតនេះផ្ទាល់ គឺចាំបាច់ត្រូវតែផ្តល់ឱ្យឃើញថាជាការពិតមុនការយល់ព្រមទទួលយកឯកសារ ហើយមិនមែនជាលក្ខខណ្ឌតម្រូវមួយដាច់ដោយឡែកសម្រាប់ការយល់ព្រមទទួលយកនោះឡើយ[23]។

១១-ក្នុងការវាយតម្លៃអំពីយថាភូតិទៅលើទិដ្ឋភាពមួយដែលអាចនឹងត្រូវបានពិចារណាថា តើឯកសារនេះគឺជាឯកសារច្បាប់ដើម ឬមិនមែន។ ក៏ប៉ុន្តែមិនមានការហាមឃាត់ជាទូទៅណាដែលប្រឆាំងនឹងការទទួលយកនូវឯកសារជាច្បាប់ចម្លងនោះឡើយ។ ថ្វីតត្បិតតែវិធាន ៨៧.៣(គ) នៃវិធានផ្ទៃក្នុងអាចមានលក្ខណៈទូលំទូលាយបន្តិចដើម្បីរួមបញ្ចូលនូវ "វិធាននៃភ័ស្តុតាងដ៏ប្រសើរបំផុត" នៅក្នុងនោះក្តីក៏វាច្បាស់ណាស់ថា មិនមានការកំណត់ថាត្រូវតែផ្តល់ឯកសារដើមនោះដែរ។ នៅឯតុលាការ ICTY ដែលជាប្រក្រតីឯកសារច្បាប់ចម្លងត្រូវបានគេពឹងផ្អែកលើនោះ វិធាននៃភស្តុតាងដ៏ប្រសើរបំផុតត្រូវបានគេយកមកប្រើដូចជាការតម្រូវឱ្យមាន "ជាស្រេចនូវភស្តុតាងដ៏ប្រសើរបំផុតទៅតាមកាលៈទេសៈនៃករណីរឿងក្តី"[24] និងដែលវាអាស្រ័យទៅលើ"កាលៈទេសៈនានាដែលមានតែមួយគ្មានពីរ ដែលភ្ជាប់ទៅនឹងឯកសារនីមួយៗ និងទៅលើលក្ខណៈស្មុគ្រស្មាញនៃករណីរឿង ហើយនឹងការស៊ើបសួរដែលបានធ្វើ

---

[22] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Zejnil Delalić និងគូរកន*, សំណុំរឿងលេខ IT-96-21-AR, សេចក្តីសម្រេចលើពាក្យសុំរបស់ចុងចោទឈ្មោះ Zejnil Delalic ដែលស្នើសុំអនុញ្ញាតដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១៩ មករា ១៩៩៨ ដើម្បីឱ្យយល់ព្រមទទួលយកភ័ស្តុតាង (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ចុះថ្ងៃទី៤ មិនា ១៩៩៨, ត្រង់កថាខណ្ឌទី២០ ("[មាន] លក្ខខណ្ឌតម្រូវដោយដែលចែងដោយបង្កប់ន័យថា ភ័ស្តុតាងណាមួយគោងតែជាភ័ស្តុតាងដែល*គ្រាន់តែឃើញមួយក្រឡេកភ្នែក* ដែលអាចឱ្យជឿបាន -ថាភ័ស្តុតាងនេះមានសញ្ញាបង្ហាញគ្រប់គ្រាន់អំពីភាពដែលអាចឱ្យជឿទុកចិត្តបាន), *Lubanga, ibid. ត្រង់ទំព័រទី២៩...* []ចាំបាច់ត្រូវធ្វើការសង្កត់ធ្ងន់ថា គ្មានបញ្ជីដែលមានកំណត់ព្រំដែនអំពីលក្ខណៈវិនិច្ឆ័យដែលអាចធ្វើទៅបានដែលត្រូវយកមកអនុវត្តនោះទេ, ហើយសេចក្តីសម្រេចណាមួយស្តីពីទំនាស់អំពីភ័ស្តុតាងដោយឡែកណាមួយ និងដែលបង្ហាញឱ្យឃើញអំពីបញ្ហានានាដែលនៅក្នុងករណីរឿងនេះនោះទេ, បរិបទដែលក្នុងនោះឯកសារត្រូវដាក់បញ្ចូល ... និងការពិនិត្យមួយយ៉ាងលំអិតអំពីកាលៈទេសៈផ្សេងៗនៃភ័ស្តុតាងដែលមានជម្លោះ")។

[23] សូមអានបន្តទៀត នូវផ្នែកទី៤(ខ)ខាងក្រោមនេះ។

[24] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Enver Hadžihasanović*, សំណុំរឿងលេខ IT-01-47-T, សេចក្តីសម្រេចស្តីពីការទទួលយកឯកសារនានារបស់មេធាវីរបស់ Enver Hadžihasanović, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២២ មិថុនា ២០០៥ ត្រង់កថាខណ្ឌទី១៥ (តាមគោលការណ៍ណែនាំដែលត្រូវបានបង្កើតឡើងនៅក្នុង*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milomir Stakic*, សំណុំរឿងលេខ IT-97-24-T, ដីកាបង្គាប់ស្តីពីបទដ្ឋានសម្រាប់គ្រប់គ្រងការយល់ព្រមទទួលយកភ័ស្តុតាង (អង្គជំនុំជម្រះ ICTY), ចុះថ្ងៃទី១៦ មេសា ២០០២ និងនៅក្នុង *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Vidoje Blagojevic និងគូរកន*, សំណុំរឿងលេខ IT-02-60-T, គោលការណ៍ណែនាំ ស្តីពីបទដ្ឋានសម្រាប់គ្រប់គ្រងការយល់ព្រមទទួលយកភ័ស្តុតាង, (អង្គជំនុំជម្រះ ICTY), ចុះថ្ងៃទី២៣ មេសា២០០៣)។

ឡើងមុននេះ”[25]។ នៅឯតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន អង្គជំនុំជម្រះតុលាការកំពូលបាន រៀបរាប់អំពីវិធាននៃភ័ស្តុតាងដ៏ប្រសើរបំផុតនេះថាជា “ វិធានដែលហួសសម័យ (anachronism)”[26]។

១២-“តម្លៃភវនីយភាព” ឬក៏ “ទម្ងន់” នៃភ័ស្តុតាងត្រូវបានរៀបរាប់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ និងនៅក្នុង ការធ្វើសេចក្តីអត្ថាធិប្បាយផ្តល់មតិរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ថា ជាផ្នែករួមផ្សំមួយនៃការជាប់ ពាក់ព័ន្ធ[27] ឬភាពគួរឲ្យសង្ឃឹមទុកចិត្តបានក្នុងនោះ[28] ឬក៏ទាំងពីរនេះចូលគ្នា[29]។ ការធ្វើដូចនេះ លក្ខខណ្ឌដែលតម្រូវឱ្យភ័ស្តុតាងត្រូវតែមានតម្លៃភវនីយហេតុនៅក្នុងដំណាក់កាលយល់ព្រមទទួលយ កអាចនឹងត្រូវបំពេញបានគ្រប់គ្រាន់ដោយសារការបង្ហាញនូវសញ្ញាអំពីការជាប់ពាក់ព័ន្ធ និងភាពគួរឲ្យ សង្ឃឹមទុកចិត្តបាន។ ម្យ៉ាងទៀត តម្លៃភវនីយហេតុ ឬទម្ងន់ដែលត្រូវផ្តល់ឲ្យទៅលើភ័ស្តុតាង ត្រូវបាន

[25] *សូមអាន ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Milomir Stakić,* សំណុំរឿងលេខ IT-97-24-T, ដីកាបណ្តោះអាសន្នស្តីពីបទដ្ឋាន សម្រាប់គ្រប់គ្រងការយល់ព្រមទទួលយកភ័ស្តុតាង (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៥ កុម្ភៈ ២០០២, ឧបសម្ព័ន្ធ ត្រង់កថាខណ្ឌទី៧។ *ករណីរឿងក្តីរបស់* Blagojevic *និងគូរកន*, ដូចគ្នានឹងខាងលើ ត្រង់កថាខណ្ឌទី៨។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Sefer Halilović,* សំណុំរឿងលេខIT-01-4S-T, គោលការណ៍ណែនាំស្តីពីបទដ្ឋានសម្រាប់គ្រប់គ្រងការយល់ព្រមទទួលយកភ័ស្តុតាង, ចុះថ្ងៃទី១៦ កុម្ភៈ ២០០៥, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ឧបសម្ព័ន្ធ ត្រង់កថាខណ្ឌទី៨។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Momcilo Perišić,* សំណុំរឿងលេខ IT-04-81-T, ដីកាបង្គាប់លើ គោលការណ៍ណែនាំស្តីពីបទដ្ឋានសម្រាប់គ្រប់គ្រងការយល់ព្រមទទួលយកភ័ស្តុតាង និងការបង្ហាញ ហើយនិងស្តីពីសីលធម៌ របស់មេធាវីនៅក្នុងតុលាការ, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៩ តុលា ២០០៨, ត្រង់កថាខណ្ឌទី៣៦។

[26] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Sam Hinga Norman* និងគូរកន, សំណុំរឿងលេខ SCSL-04-14-AR65) , Fofana– បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ,(អង្គជំនុំជម្រះឧទ្ធរណ៍ SCSL), ចុះថ្ងៃទី១១ មិនា ២០០៥, កថាខណ្ឌទី២៤។

[27] *សូមអាន ឧទាហរណ៍ដូចជា ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Enver Hadžihasanović*, សំណុំរឿងលេខ IT-01-47-T, សេចក្តីសម្រេចស្តីពីការទទួលយកឯកសារនានារបស់មេធាវីរបស់ Enver Hadžihasanović, (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២២ មិថុនា ២០០៥ ត្រង់កថាខណ្ឌ១៧ (ដែលនិយាយថា “ការពាក់ព័ន្ធ និងតម្លៃភវនីយភាពគឺមានការជាប់ទាក់ទងគ្នាយ៉ាងជាក់លាក់”) ។

[28] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Duško Tadić,* សំណុំរឿងលេខ IT-94-1-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្តីពីពាក្យចចាមអារ៉ាម (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី៥ សីហា ១៩៩៦, ត្រង់កថាខណ្ឌទី១៥។ (ដែលនិយាយថា “ បើសិនជាភ័ស្តុតាងដែលបានផ្តល់ឲ្យមិនអាចឲ្យជឿទុកចិត្តបានទេ, គឺវាប្រាកដជាមិនមានតម្លៃភវនីយភាពហើយ”) បានលើកយកមកជាសំអាងនូវករណី*រឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Slobodan Milošević,* សំណុំរឿងលេខ IT-02-54-T, សេចក្តីសម្រេចស្តីពីការទទួលយកឯកសារនានាដែលមានទំនាក់ទំនងគ្នាជាមួយ សក្ខីកម្មនៃសាក្សីរបស់មេធាវីឈ្មោះ Dragan Jasović (ICTY អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ), ចុះថ្ងៃទី២៦ សីហា ២០០៥ ត្រង់កថាខណ្ឌទី១៨។

[29] លោកចៅក្រម Richard May និង Marieke Wierda, សៀវភៅដែលមានចំណងជើងថា *International Criminal Evidence* (Transnational Publishers, 2002), ត្រង់ទំព័រ១០៧ (ដែលនិយាយថា “[]អាស្រ័យហេតនេះ តម្លៃភវនីយភាព គឺរួមមានកត្តានានាដូចជា ការពាក់ព័ន្ធ និងខាតដែលអាចឲ្យសង្ឃឹមទុកចិត្តបាន”)។

ធ្វើការវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូង នៅក្រោយពេលដែលរាល់ភ័ស្តុតាងទាំងអស់ ត្រូវបានស្តាប់នៅក្នុងសវនាការរួចហើយ[30]។

### *ii. ការបដិសេធនូវភ័ស្តុតាងដោយសារមូលហេតុផ្សេងក្រៅពីការជាប់ពាក់ព័ន្ធគ្នា និងភាពគួរឱ្យជឿទុកចិត្តបាន*

១៣-ទោះបីជា ភាពជាប់ពាក់ព័ន្ធ និងភាពគួរឱ្យជឿទុកចិត្តបានដោយ *គ្រាន់តែឃើញមួយក្រឡេកភ្នែកដំបូង* គឺជាការពិចារណាដ៏សំខាន់ជាដំបូង សម្រាប់ការយល់ព្រមទទួលយកនូវឯកសារនានានោះក៏ដោយ ក៏វិធាន៨៧.៣ បានចែងដែរអំពីការបដិសេធភ័ស្តុតាងដោយសារមូលហេតុដទៃទៀត។ វិធាន៨៧.៣(ឃ) បានចែងហាមឃាត់ដោយដាក់លាក់ចំពោះភ័ស្តុតាងណា "ដែលច្បាប់មិនបានអនុញ្ញាត"។

១៤-ភ័ស្តុតាងមួយប្រភេទដែលធាត់ចូលនៅក្នុងការហាមឃាត់យ៉ាងទូលំទូលាយនេះនោះគឺ ចម្លើយទាំងឡាយដែលបានមកដោយសារការធ្វើទារុណកម្ម។ វិធាន២១.៣ នៃវិធានផ្ទៃក្នុងដែលឆ្លុះបញ្ចាំងអំពីវិធាន១៥ នៃអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ("CAT") និងមាត្រា៣៨នៃ រដ្ឋធម្មនុញ្ញរបស់កម្ពុជា បានចែងហាមឃាត់យ៉ាងដាក់លាក់ចំពោះរាល់ចម្លើយដែលធ្វើឡើងដោយសារ "ការជំរុញឬបញ្ចុះបញ្ចូល, ការបង្ខិតបង្ខំលើរូបរាងកាយ ឬការគំរាមកំហែង" គឺមិនឱ្យទទួលយកឡើយនៅចំពោះមុខ អវតក។ នៅក្នុងករណីរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា ការហាមឃាត់នេះគឺបានន័យថា ចម្លើយទាំងឡាយណាដែលត្រូវបានធ្វើឡើងក្រោមការធ្វើទារុណកម្ម គឺមិនអាចឱ្យទទួលយកជាការពិតបានឡើយចំពោះខ្លឹមសារដែលនៅក្នុងចម្លើយទាំងនោះ ប៉ុន្តែនៅតែអាចទទួលយកធ្វើជាភ័ស្តុតាងបានដដែល ចំពោះអង្គហេតុដែលត្រូវបានធ្វើឡើងនៅក្នុងចម្លើយទាំងនោះ និងថាចម្លើយនោះត្រូវបានធ្វើឡើងក្រោមការធ្វើទារុណកម្ម[31]។ ហេតុដូចនេះ មុនពេលធ្វើការសម្រេចចិត្តក្នុងការទទួលយកនូវចម្លើយនានា (ឬឯកសាររួមផ្សំបន្ទាប់បន្សំផ្សេងៗទៀត)ជាការសំខាន់បំផុតនោះ គឺត្រូវតែកំណត់សម្រេចទៅលើគោលបំណងដែលឯកសារទាំងនោះកំពុងត្រូវបានដាក់បញ្ចូល។

[30] សូមអានបន្ថែមទៀត នូវកថាខណ្ឌទី១៥ ខាងក្រោម។

[31] សូមអាន ឯកសារលេខ **E176** សេចក្តីសម្រេចករណីឌុច លើសំណើសុំនានាអនុលោមតាមវិធាន៨៧.២ នៃវិធានផ្ទៃក្នុង, កំណត់សំគាល់លេខ ២០ *ខាងដើម* ត្រង់កថាខណ្ឌទី៨ ។ ឯកសារលេខ **E1/22.1** ប្រតិចារឹកនៃសវនាការជំនុំជម្រះក្តី, ចុះថ្ងៃទី២០ ឧសភា ២០០៩ ត្រង់កថាខណ្ឌទី៦ ។ ឯកសារលេខ **E1/27.1** ប្រតិចារឹកនៃសវនាការជំនុំជម្រះក្តី, ចុះថ្ងៃទី២៨ ឧសភា ២០០៩ ត្រង់កថាខណ្ឌទី៨-៩។

### *iii.* *ប្រការសំខាន់គឺត្រូវញែកឱ្យដាច់ដោយឡែកពីគ្នារវាងបញ្ហាការទទួលយក និងបញ្ហាទម្ងន់*

១៥- បន្ទុកលើភាគីដែលជាអ្នកបានស្នើសុំដើម្បីដាក់បញ្ចូលជាភ័ស្តុតាងនោះ គឺត្រូវបង្ហាញឱ្យឃើញក្នុងកំរិត *ជាអប្បបរមា* អំពីការជាប់ពាក់ព័ន្ធ និងភាពគួរឱ្យសង្ឃឹមទុកចិត្តបាន។ នេះមិនតម្រូវឱ្យភាគីត្រូវបង្ហាញសក្ខីកម្មឱ្យឃើញថា ភ័ស្តុតាងមានតម្លៃភវនីយភាពខ្ពស់នោះឡើយ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានាធ្លាប់បានធ្វើការកត់សំគាល់រួចហើយថា ការវាយតម្លៃអំពីតម្លៃភវនីយភាព ឬអំពីទម្ងន់នៃភ័ស្តុតាងភ័ស្តុតាងណាមួយគឺជាការសួរដេញដោលដាច់ដោយឡែកមួយ។ ការសួរដេញដោលនេះ និងធ្វើឡើងបន្ទាប់ពីភ័ស្តុតាងត្រូវបានយល់ព្រមទទួលយកដោយមានគោលបំណង ដើម្បីកំណត់ថាតើការសួរដេញដោលនេះចង់សំដៅផ្តល់សក្ខីកម្មឱ្យឃើញថាជាការចោទប្រកាន់ពិត ឬមិនពិតនៅក្នុងករណីនេះ[32]។ បទដ្ឋានសំរាប់ការយល់ព្រមទទួលយកនេះគឺជាការត្រឹមត្រូវនៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អវតក ជាពិសេសនៅក្នុងករណីដែលភ័ស្តុតាងត្រូវបានប្រមូល ឬពិនិត្យឡើងវិញដោយចៅក្រមស៊ើបអង្កេតដែលឯករាជ្យ និងមិនលំអៀងណាម្នាក់ និងចៅក្រមសាលាដំបូងទាំងឡាយដែលកាត់ក្តីលើអង្គហេតុ ដែលជាចៅក្រមអាជីពដែលមានបទពិសោធន៍ គឺមិនមែនជាគណៈវិនិច្ឆ័យដែលមិនមែនជាអាជីពនោះទេ[33]។

---

[32] សូមអាន ឯកសារលេខ **E188** សាលក្រមករណី ឌុច, កំណត់សំគាល់លេខ២១ *ខាងដើម* ត្រង់កថាខណ្ឌទី៤១ ("តម្លៃភវនីយភាពនៃភស្តុតាងនេះ ហើយហេតុនេះ ទម្ងន់ដែលត្រូវយល់ព្រមផ្តល់ឱ្យភស្តុតាងនេះ នៅទីបំផុតត្រូវបានធ្វូការវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូង")។ឯកសារលេខ **E43/4** សេចក្តីសំរេចលើភស្តុតាង ករណីឌុច, កំណត់សំគាល់លេខ២១ *ខាងដើម* ត្រង់កថាខណ្ឌ៧ ("បន្ទាប់ពីបានបង្ហាញជូននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងហើយ តម្លៃភវនីយភាពនៃភស្តុតាងនេះ, ហើយបន្ទាប់ពីនេះ ទម្ងន់ដែលត្រូវយល់ព្រមផ្តល់ឱ្យភស្តុតាងនេះនឹងត្រូវបានធ្វើការវាយតម្លៃ")។ ឯកសារលេខ **E176** សេចក្តីសំរេចស្តីពីវិធាន៨៧.២ ករណីឌុច, កំណត់សំគាល់លេខ២១ *ខាងដើម* ត្រង់កថាខណ្ឌទី៣ ("បន្ទាប់ពីបានផ្តល់ភស្តុតាង អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃលើតម្លៃភវនីយភាពនៃរាល់ភស្តុតាងទាំងអស់ ហើយសំរេចកំណត់អំពីទម្ងន់ដែលត្រូវយល់ព្រមផ្តល់ទៅលើភស្តុតាងនោះ")។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Pauline Nyiramasuhuko,* សំណុំរឿងលេខ ICTR-98-42-AR73.2, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍របស់ Pauline Nyiramasuhuko ស្តីពីភាពអាចទទួលយកបាននៃភស្តុតាង (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR), ចុះថ្ងៃទី៤ តុលា ២០០៤ ត្រង់កថាខណ្ឌទី៦ ("[] ការញែកឱ្យដាច់ពីគ្នា ត្រូវតែបានធ្វើឡើងរវាងម្ខាងគឺភាពអាចទទួលយកបាននៃភស្តុតាង និងម្ខាងទៀត ទម្ងន់ភវនីយភាពដែលត្រូវភ្ជាប់ជាមួយនឹងភស្តុតាង [ដែលជា] ការវាយតម្លៃដែលត្រូវធ្វើដោយអង្គជំនុំជម្រះសាលាដំបូងនៅចុងបញ្ចប់នៃករណីរឿង។") ។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Popović,* សំណុំរឿងលេខ UT-05-88, សេចក្តីសំរេចស្តីពីភាពអាចទទួលយកបាននៃការលួចស្តាប់ការទំនាក់ទំនង(តាមទូរស័ព្ទ) (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY) , ចុះថ្ងៃទី៧ ធ្នូ ២០០៧ ត្រង់កថាខណ្ឌទី៣៦។

[33] ភាពខុសពីគ្នារវាងបទដ្ឋានសមស្របនៃភស្តុតាងនៅក្នុងសវនាការជំនុំជម្រះក្តីរឿងព្រហ្មទណ្ឌ ដែលត្រូវបានធ្វើសវនាការដោយចៅក្រម និងការជំនុំជម្រះក្តីរឿងព្រហ្មទណ្ឌ ដែលធ្វើសវនាការដោយគណៈវិនិច្ឆ័យ ដែលត្រូវបានធ្វើសេចក្តីកត់សំលំដោយតុលាការនានាផ្សេងទៀត។

## IV. ឧឡឹករណ៍

### ក. ការជំទាស់ទាំងនេះគឺជាការមិនចាំបាច់ មានភាពផ្ទុយគ្នា និងមានលក្ខណៈស្រពេចន៍ស្រពិល ដែលមិនអាចឲ្យទទួលយកបានថាជាភ័ស្តុតាងដែលជំទាស់ និងស្នើសុំឲ្យមានឧបាស្រ័យ

#### *i. ការជំទាស់ទាំងនេះគឺគ្រាន់តែបញ្ជាក់ឡើងវិញដដែលៗអំពីទឡ្ហីករណ៍កាលពីមុនៗ មករបស់មេធាវីការពារក្តីតែប៉ុណ្ណោះ*

១៦-មេធាវីការពារក្តីធ្លាប់បានលើកឡើងកាលពីមុនៗមក តវ៉ាជំទាស់ចំពោះការទទួលយកនូវភ័ស្តុតាងមួយចំនួនក្នុងប្រភេទដ៏ទូលំទូលាយដូចគ្នា ដែលត្រូវបានដាក់បញ្ចូលនៅក្នុងការជំទាស់ផ្សេងៗ៖ គឺថាឯកសារនានាដែលបានកមក"ដោយសារការធ្វើទារុណកម្ម"។ ឯកសារទាំងឡាយរបស់ DC-Cam, "ឯកសារដែលទទួលបានដោយ កសព" និងចម្លើយសាក្សីនានា។

១៧-នៅក្នុងញត្តិចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ និងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានតវ៉ាជំទាស់ចំពោះការប្រើប្រាស់នូវភ័ស្តុតាងដែលបានមក "ដោយសារការធ្វើទារុណកម្ម"[34] និងឯកសារនានាដែលទទួលបានពី DC-Cam[35]រៀងៗខ្លួន និងបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថាភ័ស្តុតាងទាំងនេះគឺមិនអាចឲ្យទទួលយកបានទេ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើញត្តិស្នើសុំទាំងពីរនេះនៅក្នុងអង្គប្រជុំស្តីពីការរៀបចំសវនាការកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ហើយជាបន្ទាប់មកទៀតបានបញ្ជាក់អំពីសេចក្តីសម្រេចទាំងឡាយ តាមរយៈអនុស្សរណៈមួយចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១[36]។

១៨- ចំពោះញត្តិស្នើសុំដែលទាក់ទងនឹងភ័ស្តុតាង "ដែលបានមកដោយសារការធ្វើទារុណកម្ម" អង្គជំនុំជម្រះសាលាដំបូងមិនព្រមផ្តល់តាមសំណើសុំឲ្យមានឧបាស្រ័យនោះទេ ដោយធ្វើការកត់សំគាល់ថាមេធាវី

---

សូមអាន ករណីរឿងក្តីរបស់ *Tadić*, កំណត់សំគាល់លេខ២៣ *ខាងដើម* ត្រង់កថាខណ្ឌទី១៧។ករណីរឿងក្តីរបស់ *Delalić*, កំណត់សំគាល់លេខ២២ *ខាងដើម* ត្រង់កថាខណ្ឌទី២០។និងករណីរឿងក្តីរបស់ *Norman* កំណត់សំគាល់លេខ៣១ *ខាងដើម* ត្រង់កថាខណ្ឌទី២៦។

[34] ឯកសារលេខ **E33** ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ឯកសារដែលបានមកដោយសារការធ្វើទារុណកម្មនៅក្នុងសវនាការ, ចុះថ្ងៃទី៤ កុម្ភៈ ២០១១ ។

[35] ឯកសារលេខ **E59** ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ឯកសារដែលប្រមូលបានដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា, ចុះថ្ងៃទី២៤ កុម្ភៈ (ញត្តិរបស់មេធាវីទាក់ទងអំពី DC-Cam )។

[36] ឯកសារលេខ **E74** អនុស្សរណៈពីលោក និល ណុន, ប្រធាននៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនគ្រប់ភាគីទាំងអស់ក្នុងករណីរឿង នៅក្នុងសំណុំរឿងលេខ០០២, ចុះថ្ងៃទី៨ មេសា ២០១១ ("អុស្សារណៈនៃអង្គជំនុះជម្រះសាលាដំបូង") ត្រង់ទំព័រ៣។

ការពារក្តីបានស្នើសុំ "ដោយមិនមានភាពជាក់លាក់អំពីឧបាស្រ័យដែលទាក់ទងទៅនឹងឯកសារច្បាស់លាស់ណាមួយដែលមានការពាក់ព័ន្ធដ៏មានសក្តានុពលទៅនឹងសំណុំរឿង០០២នោះទេ"[37]។ ចំណែកឯញត្តិស្នើសុំដែលទាក់ទងនឹងឯកសារនានាមកពីDc-Cam វិញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួននឹងដោះស្រាយទាក់ទងនឹងការជំទាស់ចំពោះឯកសារនានា "ដោយផ្អែកលើមូលដ្ឋាននៃករណីមួយម្តងៗដោយមានការបញ្ជាក់ពីមូលហេតុ"[38]។ ហើយនៅក្នុងឱកាសនេះដែរ អង្គជំនុំជម្រះសាលាដំបូងក៏បានណែនាំឲ្យមេធាវីមានការប្រុងប្រយ័ត្នយកចិត្តទុកដាក់ ចំពោះកាតព្វកិច្ចរបស់ខ្លួនដូចដែលមានចែងនៅក្នុងវិធាន២២នៃវិធានផ្ទៃក្នុង ដោយធ្វើការកត់សំគាល់ថា ខ្លួនបានលើកជាអនុសាសន៍រួចហើយហាមមិនឲ្យចេញសោហ៊ុយចំណាយឲ្យសំរាប់ "ការដាក់ឯកសារដែលមានបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់...ដោយមិនមានមូលដ្ឋានផ្នែកអង្គច្បាប់ ហើយដែលមិនបានធ្វើអ្វីជាធំដុំលើសពីនេះ ដែលជាការបន្ថែមបន្ទុកទៅលើអង្គជំនុំជម្រះនេះ និងទៅលើសេវាបកប្រែ"។

១៩- ដោយមិនគិតពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងការរំលឹករបស់ខ្លួនទាក់ទងនឹងការដាក់ឯកសារដែលមិនចាំបាច់ មេធាវីការពារក្តីបានលើកឡើងនូវការជំទាស់ក្នុងក្របខណ្ឌដ៏ទូលំទូលាយដូចគ្នានេះដែរ ទៅនឹងភាពអាចទទួលយកបាននៃឯកសារដែល "ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម" និងឯកសារដែលបានមកពី DC-Cam នៅក្នុងការដាក់ឯកសាររបស់ខ្លួនកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១[39] ហើយជាថ្មីម្តងទៀត នៅក្នុងការជំទាស់បច្ចុប្បន្នដោយគ្មានយោងទៅកាន់ឯកសារជាក់លាក់ណាមួយឡើយ។

២០- ឯកសារក្នុងពីរប្រភេទផ្សេងទៀតដែលមាននៅក្នុងការជំទាស់នេះគឺ ចម្លើយរបស់សាក្សី និង "ឯកសារដែលបានមកដោយ កសព" បច្ចុប្បន្នជាប្រធានបទនៃសំណើមួយដែលនៅតំកល់ទុក ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ជាការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីស្តីពីការទទួលយកចម្លើយរបស់សាក្សី នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ

---

[37] *ដូចគ្នានឹងខាងលើ* ត្រង់ទំព័រ៣។

[38] *ដូចគ្នានឹងខាងលើ* ត្រង់ទំព័រ៣។

[39] **E109/6**, បញ្ជីឯកសាររបស់មេធាវីការពារក្តីទីបួន, កំណត់សម្គាល់*ខាងលើ* លេខ ១៦ ត្រង់ (ក)-(គ) ។

សាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[40] ក្នុងការស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ប្រកាសថា ពុំមានសិទ្ធិដាច់ខាតណាមួយក្នុងការកោះហៅសាក្សី ដែលកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួនត្រូវបាន ស្នើសុំជាផ្លូវការយកធ្វើជាភស្តុតាងនោះឡើយ។ មេធាវីការពារក្តីបានឆ្លើយតបនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ដោយបានអះអាងថា សិទ្ធិក្នុងការតទល់សាក្សី (រួមទាំងសាក្សីដែល កសព បានធ្វើសម្ភាសន៍ ផង) គឺសិទ្ធិជាសារវន្តមួយក្នុងការទទួលបាននូវការកាត់ក្តីដោយត្រឹមត្រូវ[41]។ ការជំទាស់បច្ចុប្បន្នមិន បានធ្វើអ្វីឱ្យបានច្រើនជាងនោះទេ ក្រៅតែពីបញ្ជាក់ម្តងទៀតនូវគោលជំហរពីមុនរបស់មេធាវីការពារក្តី លើបញ្ហានេះ ដែលអង្គជំនុំជម្រះសាលាដំបូងនៅមិនទាន់បានសម្រេចនៅឡើយ។

២១- ការលើកឡើងនូវបញ្ហាដូចៗគ្នាតាមផ្លូវច្បាប់នៅក្នុងការដាក់ឯកសារជាបន្តបន្ទាប់នោះ គឺមិនត្រឹមតែ ដដែលៗនោះទេ វាជាការមិនគោរពដល់ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់អង្គជំនុំជម្រះ និង បានដាក់ទម្ងន់ដែលមិនចាំបាច់ទៅលើពេលវេលា និងធនធានរបស់អង្គជំនុំជម្រះសាលាដំបូង និងភាគី នានាផងដែរ។

*ii. ការជំទាស់នេះគឺផ្ទុយទៅនឹងគោលជំហរដទៃទៀតដែលមេធាវីការពារក្តីបានប្រកាន់យក*

២២- នៅក្នុងប៉ុន្មានខែចុងក្រោយនេះ មេធាវីការពារក្តីបានដាក់ឯកសារចំនួនបួន រួមទាំង ឯកសារជា ភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង, ឯកសារទាំងអស់នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ក៏ដូចជា ឯកសារ ថ្មីៗជាង១.០០០ ឯកសារផងដែរ។ ដូចដែលបានកត់សម្គាល់នៅក្នុងផ្នែកប្រវត្តិនីតិវិធីខាងលើ នៅក្នុង ការដាក់បញ្ជីនានា មេធាវីការពារក្តីបានបញ្ជាក់ថា ជនជាប់ចោទគួរតែមានសិទ្ធិក្នុង ការពឹងផ្អែកទៅ លើឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះនៅពេលសវនាការ និងសិទ្ធិក្នុងការដាក់បង្ហាញនូវ ឯកសារថ្មីៗនៅដំណាក់កាលក្រោយណាមួយ។

[40] **E96**, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៥ មិថុនា ២០១១។

[41] **E96/3**, ចម្លើយតបរបស់ អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយក កំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ, ថ្ងៃទី២២ កក្កដា ២០១១ ("ចម្លើយតបរបស់ អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២")។

២៣- ដោយសារតែភាពទូទៅនៃប្រភេទនានារបស់មេធាវីការពារក្តី ទោះបីជាវាមិនអាចកំណត់ឲ្យបានជាក់លាក់ថា មានឯកសារចំនួនប៉ុន្មានដែលការជំទាស់បានអះអាងថាមិនអាចទទួលបានក៏ដោយក៏ ការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់សហព្រះរាជអាជ្ញា គឺថាការជំទាស់របស់មេធាវីការពារក្តីទៅនឹងភាពដែលអាចទទួលយកបានច្រើនជាង៧៥% នៃចំនួនឯកសារជាភ័ស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង[42]។ មេធាវីការពារក្តីទាមទារសិទ្ធិក្នុងការពឹងផ្អែកលើឯកសារនីមួយៗដែលមាននៅក្នុងសំណុំរឿង ខណៈដែលការដាក់ការជំទាស់ ដែលពួកខ្លួនបានអះអាងពីភាពដែលមិនអាចទទួលយកបាននៃឯកសារបែបដូច្នោះក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៅពេលសវនាការ។ បើដូច្នេះ គោលជំហររបស់មេធាវីការពារក្តីគឺមានលក្ខណៈផ្ទុយគ្នាទាំងស្រុង។

### *iii. ការដាក់ឯកសារទាក់ទងនឹងភ័ស្តុតាងដែលត្រូវសួរដេញដោល និង ដំណោះស្រាយដែលស្វែងរកនោះ គឺនៅស្រពិចស្រពិលមិនអាចទទួលយកបានទេ*

២៤- ការជំទាស់បានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបញ្ជាក់រួចមកហើយថាខ្លួននឹងដោះស្រាយលើការជំទាស់នោះទៅតាមឯកសារជាក់លាក់ "តាមករណីជាក់ស្តែងកាលណាមានសំអាងហេតុ"[43]។ ប៉ុន្តែ ការជំទាស់នោះ ខកខានមិនបានធ្វើការជំទាស់នឹងភាពដែលអាចទទួលយកបាននូវផ្នែកជាក់លាក់តែឯងណាមួយនៃភ័ស្តុតាងទេ។ ផ្ទុយទៅវិញ ការជំទាស់នេះបានយោងទៅដល់ឯកសារនានាដែលត្រូវបានផ្តល់និយមន័យមិនបានល្អ និងស្ថិតនៅក្នុងប្រភេទនានាយ៉ាងទូលំទូលាយបំផុត ខណៈដែលខ្លួនបានរក្សាទុកនូវ "សិទ្ធិក្នុងការដាក់ការជំទាស់ទៅនឹងឯកសារជាក់លាក់នានា" នៅដំណាក់កាលក្រោយណាមួយ[44]។ ការណ៍នេះ ទោះបីជាអង្គហេតុពិតដែលថា សហព្រះរាជអាជ្ញាបានផ្តល់ជូននូវបញ្ជីលម្អិតនៃឯកសារនានាដែលពួកខ្លួនបានស្វែងរកធ្វើការពឹងផ្អែកទៅលើ ដែលនៅក្នុងនោះពួកគេបានធ្វើការកំណត់អត្តសញ្ញាណឯកសារនីមួយៗដោយលេខឯកសារ ប្រភេទឯកសារ

[42] សហព្រះរាជអាជ្ញា បានប៉ាន់ស្មានថាមានជាង ១៤.០០០ ឯកសារជាភ័ស្តុតាង (គឺថា មិនមែនជានីតិវិធី) នៅក្នុងសំណុំរឿង ។ ក្នុងចំណោមនេះ មានឯកសារជាង ៤.០០០ ដែលទំនងជាបានមកពី DC-Cam ។ ឯកសារជាង ៥.៨០០ (រួមមានទាំង កំណត់ហេតុជាលាយលក្ខណ៍អក្សរ, កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស, សេចក្តីថ្លែង និង ពាក្យបណ្តឹងនានា) ។ ចម្លើយសារភាពជាង ៦០០ បានមកពី ស-២១ តែឯង ។ ឯកសារជាង ៧៧០ ដែលគេអាចនិយាយបានថារួមមាន "របាយការណ៍, អត្ថបទកាសែត និង ឯកសារដែលមិនមែននៅក្នុងជំនាន់នោះ", ហើយនិង ប្រតិចារឹកចំនួន ៧៩ បានមកពីសំណុំរឿងលេខ ០០១ ។

[43] **E114**, ការជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ ១ ត្រង់ទំព័រ១ (ដែលបានយោងទៅ E74, អនុស្សរណៈរបស់អង្គជំនុំ ជម្រះសាលាដំបូង, កំណត់សម្គាល់*ខាងលើ* លេខ៣៦ ត្រង់ទំព័រទី ៣) ។

[44] *ដដែលដូចមុន* ។

ម្ចាស់ឯកសារ កាលបរិច្ឆេទនិងលេខERN ការរៀបរាប់ពីឯកសារនីមួយៗ និងបានផ្តល់ជូននូវសេចក្តីយោងទៅដល់ផ្នែកពាក់ព័ន្ធនានានៃដីកាដំណោះស្រាយ ដែលឯកសារនោះនឹងត្រូវជួយក្នុងការបង្ហាញសក្ខីកម្ម[45]។

២៥- ការដែលគ្មានភាពជាក់លាក់គ្រប់គ្រាន់ ជាពិសេស ផ្ទេរនូវបន្ទុកក្នុងការធ្វើអត្តសញ្ញាណកម្មថាតើឯកសារណាខ្លះដែលត្រូវរួមបញ្ចូលនៅក្នុងប្រភេទនានារបស់មេធាវីការពារក្តី ឲ្យទៅអង្គជំនុំជម្រះសាលាដំបូង និងធ្វើឲ្យខូចដល់លទ្ធភាពរបស់អង្គជំនុំជម្រះ ក្នុងការអនុវត្តច្បាប់ឲ្យបានត្រូវតាមអត្ថន័យទៅលើការជំទាស់ដែលបានលើកឡើងនោះ។

២៦- លើសពីនេះទៀត វាជាការមួយមិនច្បាស់លាស់ទេថា តើអ្វីទៅដែលមេធាវីការពារក្តីបានធ្វើការស្វែងរកឲ្យបានសម្រេចនៅក្នុងការជំទាស់នោះ។ រីឯតួសេចក្តីនៃការជំទាស់នោះបានបន្តដំណើរទៅរកមូលដ្ឋានមួយដែលថា ប្រភេទឯកសារនានាដែលត្រូវបានកំណត់អត្តសញ្ញាណនោះគឺ "មិនអាចទទួលបានទេ" ហើយគួរតែត្រូវបានបដិសេធចោល នៅក្នុងផ្នែក "ដំណោះស្រាយ" មេធាវីការពារក្តីស្នើថាអង្គជំនុំជម្រះសាលាដំបូងត្រូវសុំឲ្យភាគីនានាធ្វើការ "បង្ហាញពី យថាភាព ភាពគួរជឿជាក់បាន និងភាពពាក់ព័ន្ធនៃឯកសារនានាដែលខ្លួនស្នើសុំឲ្យទទួលយកជាភស្តុតាង" និង "ច្រានចោលឯកសារទាំងឡាយណា ដែលមិនបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យអប្បបរមាទាំងនេះ"[46]។ មេធាវីការពារក្តីខកខានមិនបានពន្យល់ថាតើតាមទស្សនៈរបស់ខ្លួន គេត្រូវបង្ហាញ "យថាភូត ភាពជឿទុកចិត្តបាន និងភាពពាក់ព័ន្ធ" យ៉ាងដូចម្តេច និងនៅក្នុងដំណាក់កាលណានៃដំណើរការនីតិវិធី។ ដូចដែលបានថ្លែងនៅខាងលើស្រាប់ បញ្ជីឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ បានបញ្ជាក់រួចស្រេចហើយពីភាពពាក់ព័ន្ធនៃឯកសារ ដែលពួកគាត់ស្វែងរកឲ្យមានការទទួលយក។ យោងទៅតាមច្បាប់ សហព្រះរាជអាជ្ញានឹងផ្តល់ជូននូវសូចនានៃភាពអាចទុកចិត្តបាន នៅក្នុងការឆ្លើយតបទៅនឹងការជំទាស់ជាក់លាក់ណាមួយក៏ដោយ ទៅនឹងឯកសារទាំងនោះ ឬទៅនឹងដីកាសម្រេចណាមួយក៏ដោយរបស់អង្គជំនុំជម្រះសាលាដំបូង។

---

[45] **E9/31**, បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាទីមួយ, កំណត់សម្គាល់*ខាងលើ* លេខ ៦ ។ **E109/4**, បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាទីពីរ, កំណត់សម្គាល់*ខាងលើ* លេខ ១៥ ។

[46] **E114**, ការជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ ១ ត្រង់ទំព័រទី ១៤ ។

## ខ. ពិសោធន៍ផ្នែកច្បាប់ស្តីពីភាពអាចទទួលយកបានដែលថ្លែងអះអាងដោយមេធាវីការពារក្តីតាមទិដ្ឋភាពមួយចំនួន គឺមិនត្រឹមត្រូវតាមច្បាប់ទេ

២៧- ជាងការផ្តោតសំខាន់តែទៅលើវិធាន៨៧.៣ ពិសោធស្តីពីភាពអាចទទួលយកបានដែលបានថ្លែងអះអាងដោយមេធាវីការពារក្តីមានរួមបញ្ចូលនូវទិដ្ឋភាពមួយចំនួន ដែលទំនងជាត្រូវបានលេចចេញមកពីការបកស្រាយខុស ទាំងក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿងលេខ០០១ និងទាំងនៅក្នុងករណីនានានៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ភាពមិនត្រឹមត្រូវទាំងនេះបានកើតឡើងនៅកន្លែងសំខាន់ចំនួនពីរកន្លែង។

២៨- ទីមួយ មេធាវីការពារក្តីបានសន្និដ្ឋានចេញពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីរបស់ *ឌុច* ដែលថាភ័ស្តុតាង គឺត្រូវឋិតនៅក្រោមកិច្ចពិសោធដែលមានខ្នែងបីនៃយថាភូតភាព ជឿទុកចិត្តបាន និងភាពពាក់ព័ន្ធ[47]។ ដូចដែលបានលើកឡើងនៅខាងលើស្រាប់ នៅក្នុងរឿងក្តីរបស់ *ឌុច* អង្គជំនុំជម្រះសាលាដំបូងបានថ្លែងយ៉ាងច្បាស់លាស់ថា ភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន គឺជាកត្តាចម្បងនៅក្នុងភាពអាចទទួលយកបាននៃភ័ស្តុតាង ហើយមិនតម្រូវឲ្យគេបង្ហាញពីយថាភូត នៅដំណាក់កាលនៃការទទួលយកទេ។ វិធីសាស្ត្រនេះ គឺត្រូវគ្នាទៅនឹងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ*ពិសេស* នានា រួមទាំងយុត្តិសាស្ត្រដែលត្រូវបានលើកឡើង ដោយមេធាវីការពារក្តីនៅក្នុងការជំទាស់នោះផង។ ដោយឡែក នៅក្នុងករណីរបស់ *Delalić* និងគូកន អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា៖

> *ដើម្បីតម្រូវឲ្យមានសក្ខីកម្មដាច់ខាតស្តីពីយថាភូតនៃឯកសារមួយ មុននឹងគេទទួលយកវានោះ គេនឹងតម្រូវឲ្យមានកិច្ចពិសោធមួយដ៏តឹងរឹងជាងបទដ្ឋានដែលគេបានរំពឹងទុក...។ វាមិនមានមូលដ្ឋានតាមផ្លូវច្បាប់ណាមួយសម្រាប់អំណះអំណាងរបស់អ្នកស្នើសុំដែលថាសក្ខីកម្មស្តីពីយថាភូតគឺជាលក្ខខណ្ឌតម្រូវដាច់ដោយឡែក សម្រាប់ការទទួលយកបាននូវឯកសារជាភ័ស្តុតាងនោះឡើយ*[48]។

[47] *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ៥ ។

[48] *Delalić* និងគូកន, កំណត់សម្គាល់*ខាងលើ* លេខ ២២ ត្រង់កថាខណ្ឌទី ២០, ២៥ (ដោយបានលើកឡើងពីការអនុញ្ញាតនៅក្នុងករណី *រដ្ឋអាជ្ញា ទល់នឹង Mladen Naletilić និង Vinko Martinović*, សំណុំរឿងលេខ IT-98-34-A, សាលដីកា, (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី៣ ឧសភា ២០០៦ ត្រង់កថាខណ្ឌទី ៤០២ ។

២៩- ទីពីរ ដោយយោងទៅដល់ "ក្បួនតក្កវិជ្ជារបស់លោក Aristote" មេធាវីការពារក្ដីបានអះអាងថា លំដាប់លំដោយដ៏សមស្រប សម្រាប់ធ្វើការពិចារណាលើភាពអាចទទួលយកបាននៃឯកសារណាមួយ គឺត្រូវពិនិត្យទៅលើយថាភូត បន្ទាប់មកគឺ ភាពជឿទុកចិត្តបាន បន្ទាប់មកគឺ ភាពពាក់ព័ន្ធ។ សហព្រះរាជអាជ្ញាអះអាងថា លំដាប់លំដោយនេះមិនស្របតាមក្បួនតក្កវិជ្ជារបស់អ្នកណាមួយឡើយ ទោះជារបស់លោក Aristote ឬរបស់អ្នកផ្សេងទៀតក៏ដោយ។ លើកលែងតែមានឯកសារណាមួយមានភាពពាក់ព័ន្ធទៅនឹងបញ្ហានានាចំពោះមុខនោះ មិនមានមូលដ្ឋានណាមួយនៅក្នុងការបន្តការស៊ើបសួរន្ថែមទៀតពីភាពជឿទុកចិត្តបាន ឬដែលទាក់ទងទៅនឹងបញ្ហាយថាភូត ដែលជាទូទៅ តម្រូវឱ្យមានការវាយតម្លៃមួយដែលមានភាពស្មុគស្មាញ និងចំណាយពេលវេលាច្រើន ជាជាង ភាពពាក់ព័ន្ធ។ ពិតមែនហើយ លំដាប់លំដោយដែលបានស្នើឡើងដោយមេធាវីការពារក្ដីនេះ គឺមិនត្រូវគ្នាទៅនឹងសេចក្ដីថ្លែងរបស់ចៅក្រម Shahabuddeen ដែលគាត់បានស្រង់សម្ដីនៅក្នុងការជំទាស់ថា "បើ [ភ័ស្តុតាង] មិនពាក់ព័ន្ធ ភាពមិនពាក់ព័ន្ធតែឯងនោះគឺគ្រប់គ្រាន់ល្មមនឹងផាត់វាចេញបានហើយ" [49]។

## គ. ការជំទាស់ទាំងនេះពុំមានមូលដ្ឋានច្បាស់លាស់ និងមិនបានបង្ហាញថា ប្រភេទភ័ស្តុតាងនានាដែលត្រូវបានជំទាស់នេះ មិនអាចទទួលយកបាន

*i. ឯកសារមកពី DC-Cam, CGP និង ក.ស.ព*

៣០- មេធាវីការពារក្ដីបានលើកជាទឡ្ហីករណ៍ថា ឯកសារដែលបានផ្ដល់ដោយ DC-Cam, កម្មវិធីស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា("CGP") និង ក.ស.ព មានភាពលម្អៀង ដោយសារ ស្ថាប័នទាំងនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តដោយសមាជិកនៃរបបខ្មែរក្រហម[50]។ មេធាវីការពារក្ដីខកខានមិនបានចង្អុលភ័ស្តុតាងនៃការចោទប្រកាន់ពីភាពលម្អៀងនោះឱ្យបានជាក់លាក់ ពុំមានយោងទៅលើភ័ស្តុតាងជាក់ស្ដែងនៃភាពលម្អៀង ឬការអនុវត្តការងារមិនត្រឹមត្រូវជាក់លាក់របស់ស្ថាប័នទាំងនេះទេ។

---

[49] *រដ្ឋអាជ្ញា ទល់នឹង Hassan Ngeze & Ferdinand Nahimana*, សំណុំរឿងលេខ ICTR-99-52-I, សេចក្ដីសម្រេចលើបណ្ដឹង ឧទ្ធរណ៍បន្ទាន់បន្ទំ (អង្គជំនុំជម្រះឧទ្ធរណ៍ ICTY), យោបល់ ដោយឡែករបស់ចៅក្រម Shahabuddeen, ថ្ងៃទី៥ កញ្ញា ២០០០, កថាខណ្ឌទី ១៩ (ដោយបានលើកឡើងនៅក្នុង E114, ការជំទាស់, កំណត់សម្គាល់*ខាងលើ* លេខ ១ ត្រង់កថាខណ្ឌទី ១១) ។

[50] ឯកសារលេខ **E114**, ការជំទាស់, *យោងខាងលើ* កំណត់សម្គាល់១ ត្រង់កថាខណ្ឌ ១៤-១៦។

៣១- ទាក់ទិននឹង DC-Cam វិញ មេធាវីការពារក្ដីបានរិះគន់ដល់គោលជំហររបស់ស្ថាប័ននេះ ដែលលើកឡើងថា "មានអំពើប្រល័យពូជសាសន៍នៅកម្ពុជា"[51]។ អំណះអំណាងពីមុនៗរបស់មេធាវីការពារក្ដីដែលត្រូវបានដាក់បញ្ចូលជាឯកសារយោង បានលើកជាទឡ្ហីករណ៍ស្រដៀងគ្នាថា ចំណុចនេះធ្វើឱ្យឯកសារដែល DC-Cam បានទទួល "មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្ដុតាងឡើយ"[52]។ នាពេលនេះ ការជំទាស់ទាំងនេះបានពន្លាតទឡ្ហីករណ៍របស់ខ្លួនទៅដល់ CGP ទៀត ដោយសារ ស្ថាប័ននេះបានសិក្សាស្រាវជ្រាវពីព្រឹត្តិការណ៍នានាដែលបានកើតឡើងក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ "ដើម្បីជួយកំណត់ថាតើ នរណាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាក្នុងរបប ប៉ុល ពត"[53] ហើយ ក.ស.ព បានពឹងផ្អែកលើតួនាទីរបស់ខ្លួនក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ចុងចោទ[54]។

៣២- គោលជំហររបស់មេធាវីការពារក្ដីបានអះអាងជាពិសេសទៅទៀតថា សម្ភារៈនានាដែលត្រូវបានបង្ហាញ ឬគ្រប់គ្រងដោយស្ថាប័នមួយដែលមានអាណត្តិក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានប្រព្រឹត្តនៅកម្ពុជាក្នុងអំឡុងពេលដែលពាក់ព័ន្ធ គឺមិនអាចទទួលយកបានទេ។ មេធាវីការពារក្ដីបានលើកជាទឡ្ហីករណ៍ថា ការប៉ាន់ស្មានដែលថា ឧក្រិដ្ឋកម្មទាំងនេះអាចនឹងបានកើតនោះ ជាការគ្រប់គ្រាន់ដើម្បីបង្ហាញពីភាពលម្អៀងរបស់ស្ថាប័ននោះហើយ ហើយរាល់សម្ភារៈដែលស្ថាប័ននោះប្រមូលបានទាំងអស់ក៏បង្ហាញពីភាពលម្អៀងដែរ[55]។ ទឡ្ហីករណ៍នេះមិនសមហេតុផលដែលស្មានៗ និងបានបំផ្លើសពីសារសំខាន់នៃការសន្និដ្ឋានទៅលើអង្គហេតុនៅក្នុងបរិបទនាពេលបច្ចុប្បន្ននេះ។ អង្គហេតុជាមូលដ្ឋាននៃអំពើឃោរឃៅដែលបានកើតឡើងនៅកម្ពុជាក្នុងអំឡុងពេលពាក់ព័ន្ធ ដូចជាការសម្លាប់ប្រជាជនកម្ពុជាក្នុងចំនួនដ៏ច្រើន និងចំនួនដ៏ច្រើននៃជនរងគ្រោះដែលជាសមាជិកក្រុមសាសនាជាក់លាក់ ឬជាសមាជិកនៃជនជាតិភាគតិច ត្រូវបានគេដឹង និងទទួលស្គាល់យ៉ាងទូលំទូលាយ។ អង្គហេតុទាំងនេះបាននាំឱ្យមានការស៊ើបអង្កេតទៅលើបទល្មើសនានា *ក្នុងចំណោមនោះ* មាន៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ទៅតាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយមានជំនួយពីអង្គការសហប្រជាជាតិផងដែរ។ ទាក់ទិន DC-Cam និង CGP

---

51 *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៤។

52 ឯកសារលេខ **E59**, ញត្តិរបស់មេធាវីការពារក្ដី ទាក់ទងនឹង DC-Cam, *យោងខាងលើ* កំណត់សម្គាល់ ៣៥ ត្រង់កថាខណ្ឌ ១៤។

53 ឯកសារលេខ **E114**, ការជំទាស់, *យោងខាងលើ* កំណត់សម្គាល់ ១ ត្រង់កថាខណ្ឌ ១៥។

54 *ដូចជើងទំព័រខាងលើ* ត្រង់កថាខណ្ឌ ១៦។

55 *ដូចជើងទំព័រខាងលើ* ត្រង់កថាខណ្ឌ ១៤-១៦។

វិញ ស្ថាប័នទាំងពីរនេះពុំបានបង្ហាញពីភាពលម្អៀងទេ ពាក់ព័ន្ធការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ចុងចោទ។

៣៣- ទឡ្ហីករណ៍ពីភាពលម្អៀងរបស់ស្ថាប័នជាទូទៅ និងភាពលម្អៀងក្នុងការស៊ើបអង្កេតនោះក៏ ពុំមានលក្ខណៈសមហេតុសមផលដែរ នៅក្នុងបរិបទនៃដំណើរការយុត្តិធម៌នៃបទល្មើសព្រហ្មទណ្ឌ។ បើតាមការសង្កេតនៅក្នុងរឿងក្តីព្រហ្មទណ្ឌនៃតុលាការក្នុងស្រុកនៅគ្រប់ប្រព័ន្ធច្បាប់សំខាន់ៗនានា ក្នុងពិភពលោកឃើញថា ការស៊ើបអង្កេតត្រូវបានធ្វើឡើងដោយស្ថាប័នអនុវត្តច្បាប់មួយ ដោយសារមានព័ត៌មានដែលបង្ហាញថា មានបទល្មើសណាមួយត្រូវបានប្រព្រឹត្តឡើង។ ស្ថាប័នដែលទទួលបន្ទុកក្នុងការស៊ើបអង្កេត មានតួនាទីស៊ើបអង្កេត ចោទប្រកាន់នានា និងប្រមូលភ័ស្តុតាង។ ក្នុងការបំពេញនូវភារកិច្ចនេះ ស្ថាប័ននោះមានឆន្ទានុសិទ្ធិក្នុងការចាប់ខ្លួន និងស្វែងរកការឃុំខ្លួនជនសង្ស័យ និងចុងក្រោយ គឺចោទប្រកាន់ជនទាំងនោះពីបទល្មើសជាក់លាក់ណាមួយ។ ការណ៍ដែលអះអាងថា ទង្វើបែបនេះបានធ្វើភ័ស្តុតាងដែលស្ថាប័ននោះប្រមូលបាន មានភាពលម្អៀង ឬមិនអាចជឿជាក់បានតាមវិធីផ្សេងទៀតនោះ គឺផ្ទុយទៅនឹងដំណើរការជាមូលដ្ឋាននៃប្រព័ន្ធអនុវត្តច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌហើយ។

៣៤- នៅក្នុងគំរូនៃនីតិវិធីដែលមានជាធរមាននៅ អ.វ.ត.ក នេះវិញ មានការការពារជាក់លាក់ ដើម្បីធានាថាដំណើរការស៊ើបអង្កេតពុំមានភាពលម្អៀង។ កិច្ចស៊ើបអង្កេតលម្អិតត្រូវបានធ្វើឡើង ដោយស្ថាប័នតុលាការមួយដែលឯករាជ្យ (ក.ស.ច.ស) ដែលជាអ្នកវាយតម្លៃ និងប្រមូលភ័ស្តុតាង បើកកិច្ចស៊ើបសួរ និងរៀបរៀងសេចក្តីព្រាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅ ក.ស.ច.ស រួច តួនាទីរបស់ ក.ស.ព តាមតិចតួចណាស់ ហើយលទ្ធភាពដែលការិយាល័យនេះអាចធ្វើបាន គឺស្មើគ្នានឹងលទ្ធភាពរបស់មេធាវីការពារក្តីដែរ ក្នុងការប្រមូលភ័ស្តុតាង ឬការស្នើសុំឱ្យបើកកិច្ចស៊ើបសួរ នៅក្នុងដំណាក់កាលមុនសវនាការ និងពេលសវនាការនៃកិច្ចដំណើរការនីតិវិធី។ ទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា សម្ភារៈនោះគួរតែត្រូវបានដកចេញ ប្រសិនបើសម្ភារៈនោះគ្រប់គ្រងដោយស្ថាប័នមួយដែលមានគោលជំហរច្បាស់លាស់ចំពោះអង្គហេតុ ឬការទទួលខុសត្រូវរបស់ជនជាប់ចោទ ពុំបានយកចិត្តទុកដាក់ចំពោះការការពារជាមូលដ្ឋាននៅក្នុងដំណើរការការងារ និងគិតមិនដល់ចំពោះលទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការវិនិច្ឆ័យលើរឿងក្តីនេះ។

៣៥- មេធាវីការពារក្តីបានខកខានមិនបានបង្ហាញពីភាពលម្អៀងទាក់ទិននឹងឯកសារជាក់លាក់ផងដែរ។ នាពេលបច្ចុប្បន្ននេះ ទោះបីពុំទាន់មានការសម្រេចដល់អង្គសេចក្តីនៃអញ្ញត្រកម្មទាក់ទិននឹងឯកសារបាន

មកពី DC-Cam ក៏ដោយ ក៏សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានវិភាគទៅលើឯកសារបានមកពី DC-Cam ដែរ ទៅតាមតម្លៃនៃឯកសារនីមួយៗ ដោយបានបដិសេធមិនច្បាស់លាស់អំពីការហាមឃាត់ជារួមទេ[56]។ ដូចដែរបានធ្វើការកត់សម្គាល់ខាងលើរួចមកហើយ គឺថាអង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់រួចមកហើយថា អង្គជំនុំជម្រះ "នឹងឆ្លើយតបចំពោះការជំទាស់ទាំងនោះទៅតាមករណីនីមួយៗ នៅពេលមានសំអាងហេតុត្រឹមត្រូវ"[57]។

៣៦- ការជំទាស់ទាំងនេះខកខានមិនបានបង្ហាញអត្តសញ្ញាណឯកសារជាក់លាក់ កុំថាឡើយដល់ទៅផ្តល់ភ័ស្តុតាងពីភាពប៉ះពាល់ជាក់ស្តែង ការជ្រៀតជ្រែក ឬភាពលម្អៀង ក្នុងការបង្ហាញសម្ភារៈនានាដែលគ្រប់គ្រងដោយស្ថាប័នដែលបានបញ្ចេញឈ្មោះឲ្យដឹងទាំងនេះ។ ការពិត ដូចបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាបានបង្ហាញស្រេចគឺថា សម្ភារៈជាច្រើនដែលត្រូវបានជំទាស់ដោយមេធាវីការពារក្តី មិនត្រូវបានបង្កើតដោយស្ថាប័នទាំងនេះទេ គឺគ្រាន់តែគ្រប់គ្រងដោយស្ថាប័នទាំងនេះតែប៉ុណ្ណោះ។ ពុំមានការប៉ុនប៉ងដើម្បីមានការបញ្ជាក់ឲ្យច្បាស់នៅឡើយទេ ពីទំនាក់ទំនងរវាងភាពលម្អៀងរបស់ស្ថាប័នទាំងនេះ និងភាពអាចជឿជាក់បាននៃសម្ភារៈប្រភេទនេះ។

៣៧- មេធាវីការពារក្តីក៏បានជំទាស់ផងដែរ ទៅនឹងភាពអាចទទួលយកបាននៃឯកសារដែលបានចងក្រងដោយអ្នកនិពន្ធនានាដែលមានទំនាក់ទំនងការងារជាមួយ ក.ស.ព[58]។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះបានឆ្លើយតបចំពោះបញ្ហានេះរួចហើយ នៅពេលមេធាវីការពារក្តីស្នើសុំធ្វើមោឃភាពកិច្ចស៊ើបសួរ ដោយផ្អែកលើការសន្មតថាមានភាពលម្អៀងរបស់មន្ត្រីស៊ើបអង្កេតនៃ ក.ស.ច.ស ដែលមានមន្ត្រីមួយរូបក្នុងចំណោមនោះធ្លាប់បានបំពេញការងារឲ្យ ក.ស.ព[59]។ អង្គបុរេ

[56] ឯកសារលេខ **E43/4**, សេចក្តីសម្រេចលើភ័ស្តុតាងរបស់ ឌុច, *យោងខាងលើ* កំណត់សម្គាល់លេខ២១ ត្រង់កថាខណ្ឌ១៣-១៧។

[57] សូមមើល *យោងខាងលើ* កំណត់សម្គាល់លេខ ៣៦ និងអត្ថបទភ្ជាប់។

[58] ឯកសារលេខ **E114**, ការជំទាស់, *យោងខាងលើ* កំណត់សម្គាល់លេខ ១ ត្រង់កថាខណ្ឌ ១៦។

[59] **D402/1/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចបដិសេធសំណើរបស់គាត់សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយ ឬដោយមានជំនួយពីលោក David Boyle និងលោក Stephen Heder និងលើសំណើរបស់លោក អៀង សារី សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពភ័ស្តុតាងទាំងឡាយដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្តឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងការបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ ៣២-៣៣។

ជំនុំជម្រះបានពិពណ៌នាថា ការចោទប្រកាន់នោះជាការស្មានៗតែប៉ុណ្ណោះ ដោយហេតុថា ពុំមានផ្ដល់នូវភស្តុតាងគាំទ្រដល់ការចោទប្រកាន់នោះ ដូចក្នុងករណីនេះដែរ[60]។

៣៨- សហព្រះរាជអាជ្ញាសង្កេតឃើញថា បុគ្គលិកនៅ ក.ស.ព ដែលត្រូវបានលើកជាឧទាហរណ៍នៅក្នុងការជំទាស់ គឺបណ្ឌិត Craig Etcheson ត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាជាបុគ្គលមានលក្ខណៈសត្យានុម័ត និងមិនលម្អៀង នៅពេលគាត់ត្រូវបានទទួលយកជាសាក្សីជំនាញក្នុងសំណុំរឿង ០០១ នោះ[61]។ គោលជំហរនេះត្រូវបានគាំទ្រដោយអង្គជំនុំជម្រះនៃតុលាការ ICTY ដែលបានសម្រេចថា "ត្រឹមតែហេតុការណ៍ដែលថាសាក្សីជំនាញណាម្នាក់បំពេញការងារ ឬបានបំពេញការងារឱ្យភាគីណាមួយ ឬបានផ្ដល់សក្ខីកម្មគាំទ្រដល់ភាគីណាមួយក្នុងករណីផ្សេងទៀត មិនអាចដកហូតសិទ្ធិរបស់គាត់ពីការផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សីជំនាញបានឡើយ"[62]។

### *ii* សម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម

៣៩- ក្រុមមេធាវីការពារក្ដីបានលើកឡើងថា "សម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម"ទាំងអស់ "ក្រោមទម្រង់ទាំងអស់របស់វា និងក្នុងគ្រប់កាលៈទេសៈ" ពុំអាចទទួលបាននៅចំពោះមុខអ.វ.ត.ក ឡើយ"លើកលែងតែប្រឆាំងនឹងអ្នកដែលត្រូវបានចោទពីការធ្វើទារុណកម្មធ្វើជាភស្តុតាងបញ្ជាក់ថា សេចក្ដីថ្លែងការណ៍ត្រូវបានធ្វើឡើង"[63]។ ពាក្យ "សម្ភារៈដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម" មានភាពមិនច្បាស់លាស់ និងលើសពីអ្វីដែលបានចែងក្នុងសេចក្ដីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូង។ សហព្រះរាជអាជ្ញាយល់ឃើញថាពាក្យនេះ គួរត្រូវបានប្រើជំនួសដោយពាក្យនៅ ក្នុងវិធាន ២១ (៣)

---

60 *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣៣។

61 ឯកសារលេខ **E40/1**, សេចក្ដីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងលើសំណើរបស់ភាគីសុំស្ដាប់ចម្លើយសាក្សី និងអ្នកជំនាញមូលហេតុ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ២៥-២៧។ *សូមមើលផងដែរ* ឯកសារលេខ **E1/20.1**, ប្រតិចារឹកសវនាការលើអង្គសេចក្ដី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ៦០។

62 *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Vujadin Popović និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-05-88-T សេចក្ដីសម្រេចលើវិធានការការពារ ៩៤ *ស្ទួន* ការជូនដំណឹងទាក់ទងសាក្សីជំនាញ Richard Butler របស់រដ្ឋអាជ្ញា (អង្គជំនុំជម្រះសាលាដំបូង ICTY), ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ២៧។ *សូមមើលផងដែរៈ រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Milan Martić,* សំណុំរឿងលេខ IT-95-11-T សេចក្ដីសម្រេចលើញត្តិរបស់អយ្យការចំពោះការទទួលយកប្រតិចារឹក អនុលោមតាមវិធាន ៩២ *ស្ទួន* (ឃ) និងរបាយការណ៍អ្នកជំនាញអនុលោមតាមវិធាន ៩៤ *ស្ទួន*, (អង្គជំនុំជម្រះសាលាដំបូង ICTY), ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៦ កថាខណ្ឌ ៣៩-៤២។

63 **E114** ការជំទាស់ កំណត់សម្គាល់លេខ១ នៃកថាខណ្ឌខាងលើ នៅត្រង់កថាខណ្ឌ១៧។

នៃវិធានផ្ទៃក្នុង ឬនិយមន័យនៃចម្លើយសារភាព "ទទួលបានតាមរយៈការធ្វើទារុណកម្ម" ដែលមានចែងនៅក្នុងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។

៤០- ការហាមឃាត់មិនឱ្យប្រើចម្លើយទទួលបានដោយសារធ្វើទារុណកម្ម ត្រូវបានលើកឡើងនៅក្នុងផ្នែក II ខាងលើនេះ។ មានការកត់សម្គាល់ថាក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកភ័ស្តុតាងដែលជាចំណាររបស់ជនជាប់ចោទលើចម្លើយសារភាពដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម[64] នៅមន្ទីរស២១។ អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់ឯកសារទាំងស្រុង ឱ្យតែឯកសារទាំងនោះ មិនបានបង្ហាញការពិតអំពីចម្លើយសារភាពដែលផ្តល់ដោយអ្នកទោសតាមរយៈការប្រើទារុណកម្ម[65]។

៤១- ក្នុងសំណុំរឿងបច្ចុប្បន្ន សហព្រះរាជអាជ្ញាមានបំណងអនុវត្តតាមបទដ្ឋានដែលមានការទទួលស្គាល់ និងធ្វើការកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីមិនមានបំណងបញ្ជាក់ច្បាស់អំពីឯកសារជាក់លាក់ដែលខ្លួនយល់ថាអាចជំទាស់បានឡើយ ទោះជាមានបញ្ជីឯកសារលម្អិតរបស់សហព្រះរាជអាជ្ញាបង្ហាញពីលក្ខណៈនៃឯកសារ និងភាពជាប់ទាក់ទងរបស់ឯកសារទៅនឹងសំណុំរឿងក៏ដោយ។ ការទទួលយកសំណើដែលមានលក្ខណៈទូទៅរបស់ក្រុមមេធាវីការពារក្តី អាចដាក់កម្រិតមិនសមស្របលើការទទួលយកសម្ភារៈដែលមានភាពពាក់ព័ន្ធ និងអាចជឿបាន ហើយអាចបណ្តាលឱ្យមានលទ្ធផលផ្ទុយគ្នា ដោយមិនដាក់បញ្ចូលភ័ស្តុតាងនៃការធ្វើទារុណកម្មដែលជាប្រយោជន៍ដល់ចារីដែលត្រូវបានចោទ។

*iii* របាយការណ៍ អត្ថបទ និងឯកសារនានាដែលមិនបានបន្សល់ទុកពីសម័យនោះ

៤២- ជាថ្មីម្តងទៀត ការជំទាស់របស់ក្រុមមេធាវីការពារក្តីចំពោះការទទួលយក "របាយការណ៍ អត្ថបទ និងឯកសារនានាដែលមិនបានបន្សល់ទុកពីសម័យនោះ"ទាំងអស់ មានលក្ខណៈទូលំទូលាយដែលមិនអាចទទួលយកបានឡើយ។ ចំពោះភ័ស្តុតាងទាំងអស់ដទៃទៀត ភាពទទួលយកបាននៃឯកសារទាំងនោះ ត្រូវតែធ្វើការវាយតម្លៃតាមករណីនីមួយៗ។ អង្គជំនុំជម្រះសាលាដំបូងដែលមានតួនាទីសំខាន់

64 **E176** សេចក្តីសម្រេចលើរឿងក្តីឌុច លើសំណើអនុលោមតាមវិធានផ្ទៃក្នុង ៨៧(២) កំណត់សម្គាល់លេខ២០ នៃកថាខណ្ឌខាងលើនៅត្រង់កថាខណ្ឌ៨។

65 ដូចជើងទំព័រខាងលើ។

បំផុតក្នុងការកំណត់លក្ខណៈ និងវិសាលភាពនៃឯកសារនីមួយៗ អាចពឹងផ្អែកបានដើម្បីបញ្ជាក់ពីអង្គហេតុដែលពាក់ព័ន្ធក្នុងពេលសវនាការ។

៤៣- ជំហររបស់ក្រុមមេធាវីការពារក្តីអំពីប្រភេទនៃឯកសារ ត្រូវបានមើលឃើញថាមានភាពផ្ទុយគ្នា។ ក្រុមមេធាវីការពារក្តីអះអាងថា ទាំងតម្លៃជាភស្តុតាងនៃ"របាយការណ៍ និងអត្ថបទសារព័ត៌មានមួយចំនួនអាចមានទម្ងន់ស្រាលជាងអានុភាពនៃភាពពលម្អៀងរបស់វា" ហើយឯកសារទាំងនេះទំនងជាត្រូវទទួលយកច្រើនជាង ប្រសិនបើវាទាក់ទិននឹង "បញ្ហាបរិបទ"[66]។ ទោះជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តីធ្វើសេចក្តីសន្និដ្ឋានថា "ឯកសារទាំងនេះ មិនអាចជឿជាក់បាន និងមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាងឡើយ ហើយជាឯកសារដែលមិនអាចទទួលយកបានដោយអនុលោមតាមវិធាន ៨៧ (៣) (គ)"[67]។ ការលើកឡើងនេះបង្ហាញពីការស្នើឲ្យហាមឃាត់ទាំងស្រុងនូវការប្រើភស្តុតាងទាំងនោះ។

៤៤- ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីជំទាស់នឹងការទទួលយកឯកសារប្រភេទនេះ ត្រូវបានគេជឿថាមានមូលដ្ឋានលើសេចក្តីសម្រេចមួយចំនួនរបស់សាលាក្តីមិនអចិន្ត្រៃយ៍។ ក្រុមមេធាវីការពារក្តីលើកឡើងតែសេចក្តីសម្រេចនានាទាក់ទងនឹងសម្ភារៈភស្តុតាងមួយចំនួនដែលត្រូវបានសម្រេចថាមិនអាចទទួលយកបាន ប៉ុន្តែក្រុមមេធាវីការពារក្តីមិនបានលើកឡើងនូវសេចក្តីសម្រេចអំពីការមិនទទួលយកឯកសារនានា ដែលមិនបានបន្សល់ទុកពីសម័យនោះជាប្រភេទមួយនៃឯកសារឡើយ។ លើសពីនេះទៅទៀតសេចក្តីសម្រេចទាំងនេះ ឆ្លុះបញ្ចាំងអំពីការចង់ឲ្យមានការវាយតម្លៃនូវតម្លៃជាភស្តុតាងនៃឯកសារជាក់លាក់នីមួយៗ ធៀបនឹងភាពពលម្អៀងជាក់ស្តែងក្នុងកាលៈទេសៈពិសេសនានា[68]។

៤៥- វិធីសាស្ត្រនេះស៊ីសង្វាក់ជាមួយនឹងករណីយុត្តិសាស្ត្ររបស់សាលាក្តីពិសេសនានា និងតុលាការពិសេសសម្រាប់សេរ៉ាឡេអូន។ ដោយសារហេតុនេះ ទើបសេចក្តីរាយការណ៍សាព័ត៌មានផ្សេងៗ ត្រូវបានអង្គជំនុំជម្រះតុលាការ ICTY ទទួលយកជាភស្តុតាងនៃការចាប់ផ្តើមកើតមាននូវការស្អប់ខ្ពើមជាតិពន្ធកាន់តែខ្លាំងឡើងនៅក្នុងរឿងក្តី *Stakić*[69]។ ភស្តុតាងស្រដៀងគ្នានេះ ត្រូវបានប្រើប្រាស់ ដើម្បី

---

66 **E114** ការជំទាស់ កំណត់សម្គាល់លេខ១ នៃកថាខណ្ឌខាងលើ នៅត្រង់កថាខណ្ឌ១៨ ។

67 ដូចជើងទំព័រខាងលើ។

68 ដូចជើងទំព័រខាងលើ នៅត្រង់កថាខណ្ឌ១៨ ជើងទំព័រ៥១ និងរឿងក្តីទាញសំអាងហេតុបន្ទាប់ពីនេះ។

69 រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Milomir Stakić* សំណុំរឿងIT-97-24-T សាលក្រម(អង្គជំនុំជម្រះសាលាដំបូង ICTY) ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៣ នៅត្រង់កថាខណ្ឌ៤៧៦, ៤៩៣។

បញ្ជាក់ពីអង្គហេតុនានាដែលបានរាយការណ៍ ដូចជា "ការធ្វើដំណើរចាកចេញបណ្ដោះអាសន្ន"របស់ "ប្រជាជនមូស្លីមភាគច្រើន" ជាភស្តុតាងនៃការនីរទេស។ ភស្តុតាងទាំងនេះត្រូវបានពិចារណារួមជាមួយនឹងសក្ខីកម្មគាំទ្រផ្ទាល់មាត់[70]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការICTY ក៏បានតម្កល់វិធីសាស្ត្រនេះ ដោយរកឃើញនៅក្នុងករណី *Prlic* ថាអត្ថបទកាសែតមួយចំនួន ត្រូវបានទទួលស្គាល់ថាជាភស្តុតាង ហើយក៏មានការទាត់ចោលឯកសារផ្សេងទៀតដែរ ដែលខ្វះសូចនាំនៃភាពជឿជាក់បានដូចគ្នា[71]។

៤៦- ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះនៃតុលាការ ICTR បានប្រើប្រាស់អត្ថបទសាព័ត៌មាន និងឃ្លីបគំនូរជីវចលផ្សេងៗ នៅក្នុងសាលក្រមដំបូងរបស់ខ្លួន[72] និងសាលក្រមបន្ទាប់មកទៀត។ នៅក្នុងសេចក្តីសម្រេចកាលពីពេលថ្មីៗនេះ តុលាការ ICTR បានទទួលយកជាភស្តុតាងនូវសេចក្តីអត្ថាធិប្បាយមួយលើសេចក្តីព្រាងរបាយការណ៍អង្គការសហប្រជាជាតិរបស់រដ្ឋាភិបាលរវ៉ាន់ដា[73]។ តុលាការ SCSL បានព្រមទទួលយកអត្ថបទសាព័ត៌មាននៅក្នុងសវនាការ *Charles Taylor* តាមការដាក់ពាក្យសុំរបស់មេធាវីការពារក្តី ព្រមទាំងផ្អែកលើរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលមួយ ដែលបានបោះពុម្ពផ្សាយអស់រយៈពេលជាច្រើនឆ្នាំរួចមកហើយ បន្ទាប់ពីជម្លោះនៅក្នុងរឿងក្តី *RUF* [74]។

៤៧- កន្លងមក ការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានភាពស៊ីសង្វាក់ជាមួយនឹងការអនុវត្តរបស់តុលាការអន្តរជាតិផ្សេងៗទៀត។ នៅក្នុងរឿងក្តី០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលយក "សេចក្តីរាយការណ៍សាព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ" ចំនួន៨៥ និង"សេចក្តីរាយការណ៍សាព័ត៌មានអន្តរជាតិ" ចំនួន១៣៥ ស្មើនឹងជិត ២៥% នៃចំនួនវត្ថុតាងសវនាការសរុប

[70] ដូចខាងលើ នៅត្រង់កថាខណ្ឌ៦៨៩-៦៩៣។

[71] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Jadranko Prlić* និងអ្នកផ្សេងទៀត សំណុំរឿង IT-04-74-AR73.16, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំរបស់ Jadranko Prlić ប្រឆាំងនឹងសេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ចំពោះការពិចារណាលើការទទួលយកភស្តុតាងឯកសារ, (អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY)ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ២៩-៣០។

[72] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Jean-Paul Akayesu* សំណុំរឿង ICTR-96-4-T សាលក្រម(អង្គជំនុំជម្រះសាលាដំបូង ICTR) ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ នៅត្រង់កថាខណ្ឌ១២៣។

[73] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Callixte Nzabonimana* សំណុំរឿង ICTR-98-44D-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីចំពោះការពិចារណាលើការទទួលយកភស្តុតាងឯកសារ៖ "រដ្ឋាភិបាលផ្លូវការរបស់រវ៉ាន់ដា ផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ អ.ស.ប ស្តីពី DRC" (អង្គជំនុំជម្រះសាលាដំបូង ICTR), ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១។

[74] រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Charles Ghankay Taylor* សំណុំរឿង SCSL-03-1-T, សេចក្តីសម្រេចជាសាធារណៈ និងឧបសម្ព័ន្ធ កភ្ជាប់ទៅនឹងញត្តិស្នើសុំឱ្យទទួលយកឯកសារ អនុលោមតាមវិធាន ៩២ *ស្ទួន* -- ឯកសារដំណាលគ្នា(អង្គជំនុំជម្រះសាលាដំបូង SCSL), ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Issa Hassan Seasy* និងអ្នកផ្សេងទៀត សំណុំរឿង SCSL-04-15-T សាលក្រម(អង្គជំនុំជម្រះសាលាដំបូង SCSL) ចុះថ្ងៃ ២ ខែ មីនា ឆ្នាំ ២០០៩ នៅត្រង់កថាខណ្ឌ៥១៨-៥១៩។

ទាំងអស់ដែលត្រូវបានអនុញ្ញាតឱ្យដាក់ជាភ័ស្តុតាង។ គួរឱ្យកត់សម្គាល់ផងដែរនោះ គឺអង្គបុរេជំនុំជម្រះបានរកឃើញកំហុសផ្នែកច្បាប់ត្រង់ចំណុចដែល ក.ស.ច.ស ខកខានមិនបានផ្តល់សំអាងហេតុសម្រាប់ធ្វើការបដិសេធឯកសារទាំងនោះដែលត្រូវបានចាត់ទុកជាប្រភេទ "សេចក្តីរាយការណ៍" "អត្ថបទសារព័ត៌មាន" ឬ "ឯកសារមិនសហកាល"[75]។

៤៨- ការជំទាស់ដាច់ណាត់របស់សហមេធាវីការពារក្តី ទៅនឹងការប្រើប្រាស់សេចក្តីរាយការណ៍សាព័ត៌មាននានា ក៏ជាការខកខាន ក្នុងការព្រមទទួលស្គាល់ថា ភាពអាចទទួលយកបាន ឬភាពជាប់ពាក់ព័ន្ធ របស់សេចក្តីរាយការណ៍សាព័ត៌មានទាំងនោះ គឺអាស្រ័យទៅលើការប្រើប្រាស់ជាក់លាក់របស់ភ័ស្តុតាងនោះប៉ុណ្ណោះ។ករណីយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសនានា ដែលសហមេធាវីការពារក្តីបានដកស្រង់នោះ អាចនឹងមានជាប់ពាក់ព័ន្ធ ប្រសិនបើចេតនារបស់សហព្រះរាជអាជ្ញាក្នុងការប្រើប្រាស់ឯកសារបែបនោះជាមូលដ្ឋាន មានលក្ខណៈស្រដៀងគ្នាទៅនឹងការប្រើប្រាស់ដែលត្រូវបានស្នើឡើងនៅក្នុងរឿងក្តីទាំងនោះ។

៤៩- នៅពេលទទួលបានការអនុញ្ញាតហើយ អង្គជំនុំជម្រះសាលាដំបូង គឺជាទីកន្លែងដ៏ប្រសើរបំផុត ដើម្បីវាយតម្លៃទម្ងន់ដែលត្រូវភ្ជាប់ទៅនឹងឯកសារនីមួយៗ ព្រមទាំងលក្ខណៈនៃការប្រើប្រាស់ឯកសារទាំងនោះជាភ័ស្តុតាង។ ការហាមឃាត់ដាច់ខាតដែលសហមេធាវីការពារក្តីបានស្នើឡើង គឺប៉ះពាល់ដល់ឆន្ទានុសិទ្ធិនេះ។

### *iii.* សក្ខីកម្មរបស់សាក្សី និងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី

៥០- ការជំទាស់របស់សហមេធាវីការពារក្តី ចំពោះសក្ខីកម្មជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីរឿងក្តី០០១ គឺជាចម្លើយតបដ៏ខ្លីរបស់ខ្លួន ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៩២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[76]។ ក្រៅពីបញ្ជីរាយនាមសាក្សី និងបញ្ជីរាយនាមសាក្សីបណ្តោះអាសន្នរបស់សហព្រះរាជអាជ្ញា ដូចអង្គជំនុំជម្រះសាលាដំបូងបានចែកជូននោះ

---

[75] **D365/2/17** សាលដីកាស្តីពីការពិចារណាឡើងវិញ ទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០ នៅត្រង់កថាខណ្ឌ៦៦ និង៨១ ។

[76] **E96/3** ចម្លើយតបរបស់ អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ កំណត់សម្គាល់លេខ៤១នៃកថាខណ្ឌខាងលើ។

សហមេធាវីការពារក្តីខកខានមិនបានបង្រួមការជំទាស់របស់ខ្លួន ឲ្យនៅត្រឹមសក្ខីកម្មសាក្សីរបស់បុគ្គលទាំងឡាយដែលមិនមានឈ្មោះនៅលើបញ្ជីរាយនាមទាំងនេះនោះឡើយ។ ដោយសារសហមេធាវីការពារក្តីប្រកាន់ជំហរបដិសេធមិនព្រមទទួលយក ភាពអាចទទួលយកបាននូវរាល់សក្ខីកម្មសាក្សីទាំងអស់ ទោះបីជាសក្ខីកម្មរបស់បុគ្គលដែលនឹងត្រូវផ្តល់សក្ខីកម្មផ្ទាល់មាត់នៅក្នុងពេលសវនាការក៏ដោយ។

៥១- ដោយយល់ឃើញពីស្ថានភាពទូទៅ និងការកើតមានជាដដែលៗនៃការបដិសេធប្រភេទនេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះពិនិត្យមើលសារណាស្តីពីវិធាន ៩២ របស់ខ្លួន ព្រមទាំងសារណាតបទៅនឹងចម្លើយតបនានារបស់សហមេធាវី ដែលមានចែងនៅក្នុងគោលការណ៍នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងគោលការណ៍អន្តរជាតិដែលនៅជាធរមាន ដើម្បីជាមគ្គុទេសក៍ ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង លើបញ្ហានេះ។

## V. សំណូមពរ

៥២- តាមសំអាងហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាស្នើអង្គជំនុំជម្រះសាលាដំបូងមេត្តាៈ

(ក) ច្រានចោលការជំទាស់ទាំងនេះ និង

(ខ) បង្គាប់ដល់ភាគី ថារាល់ការជំទាស់ចំពោះភ័ស្តុតាងដែលធ្វើឡើងនាពេលអនាគត គឺចាំបាច់ត្រូវតែដាក់ជូននៅក្នុងរយៈពេលដែលអនុញ្ញាត និងក្នុងលក្ខណៈជាក់លាក់គ្រប់គ្រាន់មួយ ដោយមានបញ្ជាក់អត្តសញ្ញាណឲ្យបានជាក់លាក់នូវឯកសារ និងសំអាងហេតុនានាសម្រាប់ការជំទាស់។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |